# ទម្រង់ស្នើសុំមូលនិធិ
# មូលនិធិជំរុះឆ្នាំ២០១៩

សូមជ្រើសរើសប្រភេទមូលនិធិដែលអ្នកស្នើសុំ

មូលនិធិចល័ត ☐ មូលនិធិសម្រាប់គម្រោង ☑

**ព័ត៌មានអំពីអ្នក៖**

ឈ្មោះ: [redacted] ថ្ងៃខែឆ្នាំកំណើត [redacted]

ភេទ [redacted]

អាសយដ្ឋាន [redacted]

ទូរស័ព្ទ [redacted] សារអេឡិចត្រូនិក [redacted]

ស្ថាប័ន ________________ (សូមបំពេញថា "គ្មាន" ប្រសិនបើអ្នកមិនចំណុះស្ថាប័នណាមួយ)

តួនាទី ________________ (អាចរំលងបាន!)

អាសយដ្ឋាន ________________

________________

ឈ្មោះ (ក្នុងករណីមិនអាចទាក់ទងបាន) [redacted]

ទូរស័ព្ទ [redacted]

## ប្រវត្តិការសិក្សា – អាចរំលងបាន

| សាលា ឬស្ថាប័នអប់រំ | ឆ្នាំ | កម្រិតសញ្ញាបត្រ | កាលបរិច្ឆេទបញ្ចប់ | មុខវិជ្ជាសិក្សា |
|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| [redacted] | [redacted] | [redacted] | [redacted] | [redacted] |
| | | | | |

**ប្រវត្តិស្នាដៃ ឬការស្រាវជ្រាវ (បើមាន)** – សូមកុំកែតម្រូវទំហំប្រអប់ចម្លើយទាំងនេះ

| |
|---|
| ចំពោះស្នាដៃ ខ្ញុំធ្លាប់បានធ្វើស្នាដៃមានដូចជា<br>- ប្រភេទគំនូរប្រេង (Oil Painting )<br>- គំនូរពណ៌ទឹក (watercolors )<br>-គំនូរផ្តិតពុម្ពពីស្ពាន់ ក្តារឈើបន្ទះ និងនៅលើថ្ម ( Printmaking Etching , woodcut and lithography )<br>-ស្នាដៃថតរូប ( Photography ) ។<br>ហើយស្នាដៃទាំងនោះសុទ្ធបានធ្វើការដាក់បង្ហាញក្នុងវិចិត្រសាលសិល្បៈ(Art Gallery ) នៅក្នុងទីក្រុងភ្នំពេញ ដែលបានបង្ហាញជាលក្ខណៈក្រុម និងទោល ។ |

**ប្រវត្តិការងារ**

| | |
|---|---|
| 2015 | ការងារស្ម័គ្រចិត្តជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា(Document Center of Cambodia) |
| 2016-2017 | ការងារជាជំនួយការរបស់សាស្រ្តាចារ្យខ្មែរ និង សាស្រ្តចារ្យពីប្រទេស Mexico នៅក្នុងរោងជាបោះពុម្ពចារ( Char RUFA Printmaking studio ) នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រ-សិល្បៈ នៅក្នុងទីក្រុងភ្នំពេញ ។ |
| 2016 | កម្រោងការការពារ និងអភិរក្ស សំណង់ប្រសាទបុរាណ ជាមួយក្រសួងវប្បធម៌ និងវិចិត្រ-សិល្បៈ ។ |
| 2018 | ជាជំនួយការផ្នែកថតរូបជាមួយសិល្បកររូបថត ដែលធ្វើការងារថតរូបចម្លាក់សម្រាប់អង្គ-ការយូណេស្កូ (UNESCO ) |

## <u>ព័ត៌មានអំពីគម្រោងស្នើសុំ៖</u>

១) ឈ្មោះគម្រោង៖ **សិល្បៈការផ្តិតពុម្ពនៅកម្ពុជា** ( Printmaking arts in Cambodia )

២) អត្ថបទសង្ខេបនៃគម្រោង (មិនត្រូវសរសេរលើសពីប្រអប់នេះឡើយ)

គម្រោង សិល្បៈការផ្តិតពុម្ពនៅកម្ពុជា (Printmaking in Cambodia ) គឺជាគម្រោងមួយ ដែលរបស់រូបខ្ញុំផ្ទាល់ដែលជានិស្សិតបាន បញ្ចប់ការសិក្សាពីលើជំនាញសិល្បៈគំនូរវិចិត្រកម្ម កាលពីចុងឆ្នាំ2017 ពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ហើយក្នុងពេលជាមួយគ្នាដែលនោះខ្ញុំក៏សិក្សាជំនាញមួយដែលមានឈ្មោះជាសកលថា Printmaking ហេតុដូចនេះខ្ញុំមានបំណងចង់ធ្វើការបង្កើតស្នាដៃសិល្បៈថ្មី តាមរយៈការផ្តិតពុម្ពរូបចេញពីបន្ទះដែកស្ពាន់ និង បន្ទះក្តារឈើផងដែរ ជាមួយម៉ាស៊ីពាក់កណ្តាលស្វ័យប្រវត្តិ ឬមួយក៏យើងអាចធ្វើការបោះដៃក៏បានដែរ ។

៣) តើអ្វីជាសារៈសំខាន់នៃគម្រោងនេះ?

សារៈសំខាន់នៃគម្រោងនេះ គឺ ៖

- ជួយអភិវឌ្ឍនបន្ថែមទៀតទៅលើជំនាញសិល្បៈរបស់ខ្ញុំ ។
- បង្កើនការស្វែងយល់ពីការបង្កើតស្នាដៃសិល្បៈដោយខ្លួនឯង។
- ជាផ្នែកមួយដែលបង្ហាញថាពីការដើរទៅមុខរបស់វិស័យសិល្បៈសហាសម័យនៅក្នុងប្រទេសកម្ពុជារបស់យើង ។
- បន្ថែមកម្លាំងចិត្តសម្រាប់ខ្ញុំក៏ជំរុញរូបខ្ញុំក្នុងការដើរផ្លូវជីវិតជាសិល្បករខ្មែរមួយរូបក្នុងថ្ងៃអនាគត។

៤) តើគម្រោងនេះ មានប្រយោជន៍អ្វីខ្លះ ដល់សហគមន៍សិល្បៈ និងវប្បធម៌នៅកម្ពុជា?

សម្រាប់ខ្លួនខ្ញុំគឺវាពិតជាប្រយោជន៍ដល់សហគមន៍សិល្បៈនិង វប្បធម៌នៅកម្ពុជា ព្រោះគម្រោងមួយនេះគឺ ជាគម្រោងដែលខ្ញុំចង់ធ្វើការផ្សព្វផ្សាយអំពីបច្ចេកទេសថ្មីមួយទៀតក្នុងការបង្កើតស្នាដៃសិល្បៈដែលទើបតែកើតមាននៅក្នុងប្រទេសកម្ពុជា ។

ដែលរូបខ្ញុំបានសិក្សារៀនសូត្រក្នុងពេលស្របជាមួយគ្នានៅពេលដែលខ្ញុំបាទរៀននៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។ ខ្ញុំគិតថា បច្ចេកទេសនៃជំនាញសិល្បៈមួយនេះមិនទាន់មានភាពទូលាយ ក៏ជាការបង្ហាញដល់សាធារណៈជនទូទៅនៅក្នុងប្រទេសកម្ពុជាយើង ឲ្យពួកគាត់អំពីបច្ចេកទេសសិល្បៈមួយនេះ ហេតុនេះហើយបានខ្ញុំមានបំណងបង្កើតគម្រោងនេះឡើងមកមួយទៀត វាក៏ដូចជាការចែករំលែកនូវចំណេះដឹងថ្មីដែលខ្ញុំបានរៀនទៅដល់សាធារណៈជន ឲ្យគេបានស្គាល់នៅពេលដែលគេមកបានទស្សនាស្នាដៃសិល្បៈថ្មីរបស់ខ្ញុំ ។

៥) រយៈពេលនៃគម្រោង

គម្រោងនេះគឺមានរយៈ ៦ខែ ។

៦) គម្រោងថវិកា របស់គម្រោង (សូមបញ្ជាក់លំអិត)

គម្រោងខ្ញុំធ្វើការបែងចែកជា ៣ផ្នែកគឺ ៖

១/ ចំណាយសម្រាប់ទិញសម្ភារៈក្នុងការធ្វើស្នាដៃ ក្នុងនោះមានដូចជា ការបន្ទះឈើ បន្ទះដែកស្ពាន់ ទឹកថ្នាំសម្រាប់បោះពុម្ព ក្រដាសសម្រាប់បោះពុម្ព ។

២/ ចំណាយលើកន្លែងរោងជាងនៅពេលដែលធ្វើការបោះពុម្ពសម្រេច (Edition)

៣/ ចំណាយសម្រាប់ពេលចុះទៅតាមបណ្តាលខេត្ត និងក្នុងអំលុងពេលធ្វើស្នាដៃ ។

**សម្អិតចំនួនថវិការត្រូវប្រើប្រាស់ ៖**

ទឹកថ្នាំ Ink for etching 32.35 $ x 5 (Gamblin Etching 300ml ) 161.75$
Ink for woodcut 25 $ x 5 = 125 $
ចំណាយលើសម្រាប់រោងជាងបោះពុម្ព 250 $
បន្ទះដែកស្ពាន់ 15 $ x10 បន្ទះ( ទំហំ 25cm X 30cm ) , 150 $
ក្តារឈើបន្ទះកម្រាស់ 4លី ចំនួន ៤ សន្លឹក ( 120cm X 240cm ) 30 $
ក្រដាសសម្រាប់បោះពុម្ព Hahnemuhle ,series 300gsm size 80*120 , 50 sheets ,
prize 652 $ ។
បូករួមទាំងការចំណាយផ្សេងទៀត ដូចជាទៅលើទឹកថ្នាំលាងសម្អាត ក្រដាសខាត់ ។ល។
ដូចនេះសរុបចំនួន គឺប្រហែល 1400 ដុល្លារ ។

**បញ្ជាក់៖**

សម្ភារៈមួយផ្នែកធំដែលសំខាន់នោះគឺត្រូវបានបញ្ជាទិញពីក្រៅស្រុកទាំងអស់ មានទឹកថ្នាំសម្រាប់បោះពុម្ព និងក្រដាសជាដើម។

៧) ទីតាំងគម្រោង

| |
|---|
| ចំពោះទីតាំងគំរោងគឺអាចនៅតាមខេត្តខ្លះៗ ពីព្រោះក្នុងបង្កើតស្នាដៃទាមទារឲ្យមានការស្រាវជ្រាវសាច់រឿងខ្លះដែលយើងចង់បាន ហើយចំពោះទីតាំងក្នុងការ ផលិតស្នាដៃគឺនៅក្នុងទីក្រុងភ្នំពេញ ។ |

សិល្បៈខ្មែរអមតៈ ប្តេជ្ញាចិត្តគាំទ្រដល់បេក្ខជនទាំងអស់ ដោយគ្មានការរើសអើងអំពីអាយុ ពិការភាព ជនជាតិដើមភាគតិច ភេទ អត្តសញ្ញាណភេទ ស្ថានភាពគ្រួសារ សាសនា និងសង្គមសេដ្ឋកិច្ចឡើយ។ យើងសូមលើកទឹកចិត្តជាពិសេសចំពោះបេក្ខជនមកពីសហគមន៍ ដែលមានសំឡេងតិច ហើយយើងនឹងផ្តល់ការគាំទ្រ អាស្រ័យលើតម្រូវការ និងភាពចាំបាច់ (ទៅដល់បេក្ខជន ដែលទទួលបានភាពជោគជ័យទាំងនោះ)។ យើងអាចកែសម្រួលពាក្យស្នើសុំផងដែរ។ បើសិនអ្នកចង់បង្ហាញយោបល់បន្ថែម អំពីស្ថានភាពរបស់អ្នក សូមសរសេរនៅទីនេះ៖

| |
|---|
| ក្រោយពីពេលដែលខ្ញុំបានទៅសិក្សារយៈពេល ៦ខែនៅក្នុងសាកលវិទ្យាល័យប៉ារីស 8 នៅក្នុងប្រទេសបារាំង ( University Paris VIII Vincennes-Saint Denis ) នៅមុខវិជ្ជា Arts Plastique ខ្ញុំក៏មានគំនិត ចង់ជាស្នាដៃថ្មីមួយសម្រាប់ខ្លួនឯងផង ក៏ដូចជាការសាកល្បងស្វែងយល់គំនិតថ្មីតាមរយៈការធ្វើស្នាដៃជាមួយគម្រោងនេះ ប៉ុន្តែដោយហេតុតែខ្ញុំមិនមានលទ្ធភាពគ្រប់គ្រាន់នឹងធ្វើវាឡើងមកដោយត្រូវចំណាយធនធានច្រើន ដែលពិតជាការពិបាកសម្រាប់ខ្លួនខ្ញុំ ។ |

*ពាក្យស្នើសុំ អាចបំពេញដោយដៃ ឬដោយកុំព្យូទ័រ។ ប្រសិនបើបេក្ខជនមានភាពលំបាកក្នុងការបំពេញពាក្យស្នើសុំ សូមទាក់ទងមកលេខទូរស័ព្ទ ០១០ ៩៤១២២៤។

សូមភ្ជាប់មកជាមួយនូវ៖

1. ព័ត៌មានលំអិតរបស់គម្រោង៖ ប្រវត្តិ គោលបំណង លទ្ធផលរំពឹងទុក កាលបរិច្ឆេទសំខាន់ៗ ដែគូ ... មិនលើសពី ៣ទំព័រ
2. ជីវប្រវត្តិ ដែលមានបញ្ជាក់អំពីការងារពាក់ព័ន្ធនឹងសិល្បៈ មិនលើសពី ១ទំព័រ
3. សំភ្ភារៈនានា ដូចជារូបថត វីដេអូ ដំណាក់ស្រង់សម្តី តំណភ្ជាប់ ឬ អត្ថបទចុះផ្សាយនៃការងារមុនៗ

ហត្ថលេខា [redacted] កាលបរិច្ឆេទ៖ ថ្ងៃទី18 ខែ តុលា ឆ្នាំ2018